# ដាក់ពាក្យធ្វើពន្ធដើម្បីបានប្រាក់ដែលអ្នកត្រូវបានមកវិញ

អ្នកអាចមានសិទ្ធិទទួលបានប្រាក់រហូតដល់ទៅ **$6,000** ឬច្រើនជាងនេះ ដែលបានមកពីប្រាក់ពន្ធដែលរដ្ឋសងមកឱ្យអ្នកវិញ នៅពេលណាដែលអ្នកដាក់សុំឥណទានពន្ធលើប្រាក់ចំណូលដែលអ្នករកបាន និងប្រាក់ឥណទានសំរាប់កូន

## 1 ដើម្បីរកកន្លែងជួយធ្វើពន្ធឱ្យដោយឥតគិតថ្លៃ*

ចូលទៅវ៉ិបសាយ **irs.treasury.gov/freetaxprep** ឬទូរស័ព្ទទៅលេខ **800-906-9887** ។

## 2 ដើម្បីឱ្យដឹងថាតើអ្នកមានសិទ្ធិទទួលប្រាក់មកវិញដែរទេ

ដើម្បីចង់ដឹងថាតើអ្នកប្រហែលជាអាចទទួលបានប្រាក់សងមកវិញប៉ុន្មានដែរ សូមចូលទៅ **eitcoutreach.org/help** ។

## 3 សូមដាក់ពាក្យធ្វើពន្ធ

ចូលទៅកន្លែងជួយធ្វើពន្ធឱ្យដោយឥតគិតថ្លៃឱ្យបានមុនថ្ងៃទី 18 ខែ មេសា ដើម្បីដាក់ពាក្យធ្វើពន្ធរបស់អ្នក និងទទួលបានប្រាក់របស់អ្នកមកវិញ នៅពេលធ្វើពន្ធ ។

* អ្នកនៅតែអាចដាក់ពាក្យសុំឥណទានពន្ធបាន ទោះបើជាអ្នកមិនអាចរកកន្លែងដែលជួយធ្វើពន្ធឱ្យបានដោយឥតគិតថ្លៃ នៅក្បែរអ្នកក៏ដោយ ។

### *នៅពេលណាដែលអ្នកនឹងត្រូវដាក់ពាក្យធ្វើពន្ធរបស់អ្នក?*

ថ្ងៃ ខែ ឆ្នាំ

វេលាម៉ោង

ទីកន្លែង

លេខទូរស័ព្ទ

សំរាប់ពត៌មានបន្ថែម, សូមចូលទៅ **eitcoutreach.org/help** ឬទូរស័ព្ទទៅក្រសួង IRS តាមរយៈលេខ **1-800-829-1040** ។

GET IT BACK CB

# តើខ្ញុំមានសិទ្ធិដែរឬទេ?

ឥណទានពន្ធលើប្រាក់ចំណូលដែលរកបានពីកន្លែងធ្វើការ និងឥណទានពន្ធសំរាប់កូន គឺជាលុយសងសំរាប់អ្នកដែលធ្វើការ ។ អ្នកអាចបង់ពន្ធឱ្យរដ្ឋវិញតិច ឬទទួលបានប្រាក់សងមកវិញ។

*ការដាក់ពាក្យសុំឥណទានទាំងនេះនឹងមិនប៉ះពាល់ដល់សិទ្ធិទទួលជំនួយ ឬ ជំនួយទាំងឡាយណា ដូចជាជំនួយ SNAP (ម្ហូប) អេសអេសអាយ មេឌីខេដ ជំនួយជាលុយ ឬជំនួយបង់ថ្លៃផ្ទះសាធារណៈនោះទេ ។ ប្រសិនបើអ្នកសន្សំប្រាក់សំណងពេលធ្វើពន្ធរបស់អ្នក ប្រាក់នោះនឹងមិនត្រូវបានគេ រាប់ជាប្រាក់ចំណូលនៅក្នុងកម្មវិធីផ្តល់ជំនួយពីសហពន្ធ័ នៅពេលគណនាកំណត់ធនធាន/ទ្រព្យសម្បត្តិ សំរាប់ក្នុងរយៈពេល 12 ខែ ក្រោយពេលដែលអ្នក បានទទួលប្រាក់សំណងនោះ ។*

## ប្រសិនបើអ្នកមានកូន

- ☐ **អាយុ:** សំរាប់ *EITC* កូនត្រូវតែមានអាយុក្រោម 19 ឆ្នាំ គិតត្រឹមចុងឆ្នាំ 2016 (បើជាកូនសិស្សរៀនពេញម៉ោង អាចមានអាយុក្រោម 24 ឆ្នាំ ហើយបើជាកូនដែលពិការតែម្តង នោះអាចមានអាយុប៉ុន្មានក៏បានដែរ) ។ សំរាប់ *CTC* កូនត្រូវតែមានអាយុក្រោម 17 ឆ្នាំ គិតត្រឹមចុងឆ្នាំ 2016 ។
- ☐ **ទីកន្លែងរស់នៅ:** កូនត្រូវតែបានរស់នៅជាមួយអ្នកលើសពីកន្លះឆ្នាំ ក្នុងឆ្នាំ 2016 ។
- ☐ **ប្រាក់ចំណូលសំរាប់ឆ្នាំ 2016:** សំរាប *CTC* ប្រសិនបើអ្នករកបានចំណូលច្រើនជាង $3,000 អ្នកអាចដាក់ពាក្យធ្វើពន្ធ ហើយអាចទទួលបានលុយមកវិញរហូតដល់ $1,000 សំរាប់កូនម្នាក់ៗ ។ សំរាប *EITC* ប្រាក់ចំណូលរបស់អ្នកត្រូវតែនៅក្រោមការកំណត់ខាងក្រោមនេះ:

| **ចំនួនកូន** | **នៅលីវ** | **រៀបការ** | **EITC បាន រហូតដល់** |
|---|---|---|---|
| 1 | $39,296 | $44,846 | $3,373 |
| 2 | $44,648 | $50,198 | $5,572 |
| 3 ឬលើសពីនេះ | $47,955 | $53,505 | $6,269 |

### *តើត្រូវយកឯកសារអ្វីទៅកន្លែងធ្វើពន្ធដោយឥតគិតថ្លៃ*

- ប័ណ្ណសំគាល់ខ្លួនដែលមានសុពលភាព
- ប័ណ្ណសូសៀល់សេគ្ួរិទី លិខិតបញ្ជាក់លេខសូស្យាល់សេគ្ួរិទី ឬ លេខ ITIN
- W-2 ឬ បែបបទលេខ 1099
- ភស្តុតាងនៃការធានារ៉ាប់រងសុខភាព (បែបបទលេខ 1095-A, 1095-B ឬ 1095-C)

## ប្រសិនបើអ្នកមិនមានកូន

- ☐ **អាយុ:** អ្នកត្រូវតែមានអាយុចន្លោះរវាង 25 ឆ្នាំ ទៅ 64 ឆ្នាំ ។
- ☐ **ប្រាក់ចំណូលសំរាប់ឆ្នាំ 2016:** ប្រសិនបើអ្នករកបានប្រាក់ចំណូលតិចជាង $14,880 ($20,430 ប្រសិនបើដាក់ថារៀបការ) អ្នកអាចទទួលបានលុយសងសំរាប់ EITC រហូតដល់ $506 ។

## ប្រសិនបើអ្នកមិនមានសញ្ជាតិអាមេរិកាំង

- ☐ **EITC:** ទាំងរូបអ្នក គ្រួសារអ្នក និងកូនអ្នក ត្រូវតែមានលេខសូស្យាល់សេគ្ួរិទីដែលមានសុពលភាព ទើបធ្វើពន្ធបាន។
- ☐ **CTC:** ទាំងរូបអ្នក គ្រួសារអ្នក និងកូនអ្នក ត្រូវតែមានលេខសូស្យាល់សេគ្ួរិទី ឬ លេខសំគាល់សំរាប់អ្នកបង់ពន្ធ (ITIN) ទើបធ្វើពន្ធបាន។

## កិច្ចធានារ៉ាប់រងសុខភាព

ប្រសិនបើអ្នកមិនមានកិច្ចធានារ៉ាប់រងសុខភាពទេ នោះលុយបានមកវិញពេលធ្វើពន្ធ អាចយកទៅចេញសងថ្លៃបង់គម្រោងស្ទើរតែទាំងអស់! ចូរចុះឈ្មោះទិញកិច្ចធានារ៉ាប់រងសុខភាពចាប់ពីរវាង ថ្ងៃទី 1 ខែ វិច្ឆិកា ឆ្នាំ 2016 រហូតដល់ថ្ងៃទី 31 ខែមករា ឆ្នាំ 2017 ។ មនុស្សមួយចំនួនដែលគ្មានកិច្ចធានារ៉ាប់រង ប្រហែលជាអាចរងការផាកពិន័យ ។ បើចង់បានពតិមានបន្ថែម ចូរទាក់ទងទៅលេខ **1-800-318-2596** ឬ **www.HealthCare.gov** ។